**មាតិកា**


១. ការពិនិត្យមើលឡើងវិញលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីសេសានក្រោម ២

២. ការពិព័ណ៌នាអំពីគម្រោង

៣. យោបល់ទូទៅអំពីកិច្ចដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

៤. យោបល់ជាក់លាក់និងអនុសាសន៍

៥. ចំណុចខ្វះខាតសំខាន់ៗនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

៦. ការពិនិត្យមើលឡើងវិញនូវជំពូក ៦: ផលប៉ះពាល់បរិស្ថាន និង វិធានការកាត់បន្ថយផលប៉ះពាល់

៧. អនុសាសន៍ស្តីពីសកម្មភាព


---

## ១. ការពិនិត្យមើលឡើងវិញលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីសេសានក្រោម ២

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានពិនិត្យមើលឡើងវិញលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) សម្រាប់ការសិក្សាអំពីលទ្ធភាពអនុវត្តគម្រោងវារីអគ្គិសនីសេសានក្រោម ២ នៅខេត្តស្ទឹងត្រែងនៃប្រទេសកម្ពុជា ដែលត្រូវបានរៀបចំដោយក្រុមហ៊ុន Key Consultants Cambodia (KCC) រួមជាមួយក្រុមហ៊ុន Power Engineering Consulting Joint Stock Company 1 (PECC1) នៃប្រទេសវៀតណាម កាលពី ខែ តុលា ឆ្នាំ ២០០៨។

គោលបំណងនៃការពិនិត្យឡើងវិញនេះ គឺដើម្បីផ្តល់យោបល់អំពីភាពពេលលេញនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តដោយក្រសួងបរិស្ថាន ក៏ដូចជាអាជ្ញាធរអគ្គិសនីកម្ពុជា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងធនធានទឹកនិងឧតុនិយម ដែលគឺជាស្ថាប័ននាំមុខទទួលបន្ទុកលើស្តង់ដារ និងការអនុម័តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការផ្តល់

អាជ្ញាប័ណ្ណគម្រោង ការត្រួតពិនិត្យគម្រោង ស្តាដែគម្រោង និង ការគោរពតាមច្បាប់កម្ពុជាជាទូទៅ។ ការពិនិត្យមើលឡើងវិញនេះ មិនសំដៅធ្វើឱ្យបានលម្អិតទេ ប៉ុន្តែ គឺសំដៅគូសបង្ហាញនូវចំណុចខ្វះខាត និងបញ្ហាសំខាន់ៗទាក់ទិននឹងសហគមន៍មូលដ្ឋានដែលរស់នៅតាមដងទន្លេទន្លេសេសានិងទន្លេស្រែពក ក៏ដូចជាផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងប្រជាធិបតេយ្យទូលំទូលាយរបស់អ្នកប្រើប្រាស់និងប្រជាពលរដ្ឋកម្ពុជាផងដែរ។

## ២. ការពិពណ៌នាអំពីគម្រោង

ទំនប់វារីអគ្គិសនីសេសានក្រោម ២ ត្រូវបានស្នើឡើងសម្រាប់ការសាងសង់នៅលើទន្លេសេសាន ចម្ងាយប្រមាណជា ២៥ គីឡូម៉ែត្រខ្សែទឹកខាងលើពីទីរួមខេត្តស្ទឹងត្រែង និង ប្រហែលជា ១,៥ គីឡូម៉ែត្រ ខ្សែទឹកខាងក្រោមនៃកន្លែងជួបប្រសព្វគ្នានៃទន្លេសេសានិងទន្លេស្រែពក។ ទន្លេទាំងពីរនេះ មានប្រភពនៅក្នុងតំបន់ខ្ពង់រាបកណ្តាលនៃប្រទេសវៀតណាម និង ហូរឆ្លងកាត់ខេត្តស្ទឹងត្រែង និង ខេត្តរតនគិរី (និង ខេត្តមណ្ឌលគិរី) នៅភាគឦសានប្រទេសកម្ពុជា ដែលធ្វើឱ្យការអភិវឌ្ឍន៍វារីអគ្គិសនីនៅលើដៃទន្លេមេគង្គទាំងពីរនេះក្លាយជាការបារម្ភមួយដែលមានលក្ខណៈអន្តរជាតិ និងឆ្លងដែន។

ប្រសិនបើត្រូវបានសាងសង់ហើយ ទំនប់សេសានក្រោម ២ នឹងជន់លិចបូរណភាពដែនដីកម្ពុជាទំហំ ៣៣៥ គីឡូម៉ែត្រការ៉េ និងធ្វើឱ្យគ្រួសារជាង ១.000 ឬ ប្រជាជនជាង ៥.000 នាក់ និង ភូមិរាប់សិបនៅតាមដងទន្លេទាំងពីរនេះ នៅខ្សែទឹកខាងលើ និង ខ្សែទឹកខាងក្រោម ត្រូវរើផ្លាស់លំនៅឋាន។

ប្លង់សំណង់រួមមានការតម្លើងសមត្ថភាពផលិតអគ្គិសនីប្រហែលជា ៤00 មេហ្គាវ៉ាត់ ទោះបីជាសមត្ថភាពផលិតអគ្គិសនីជាក់លាក់ (ឬអាចទុកចិត្តបាន) ត្រូវបានគេប៉ាន់ស្មានថាមានកម្រិតប្រហែល ១00 មេហ្គាវ៉ាត់ក្តី។ គោលបំណងគម្រោងដែលបានលើកឡើង គឺសំដៅផ្គត់ផ្គង់អគ្គិសនីជូនដល់ខេត្តនៅជុំវិញ និងប្រទេសវៀតណាម។

គម្រោងនេះត្រូវបានរំពឹងថានឹងត្រូវបានសាងសង់លើគោលការសាងសង់-ដំណើរការ-ផ្ទេរ (BOT) និង នឹងត្រូវការការវិនិយោគមួយដែលមានទឹកប្រាក់ប្រមាណជា ៨១៦ លានដុល្លារអាមេរិក។ យោងតាមអនុស្សរណៈនៃការយោគយល់ឆ្នាំ ២00៧ មួយ [ឧបសម្ព័ន្ធ ១ក] រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៃប្រទេសកម្ពុជា និង អគ្គិសនីវៀតណាម (EVN) អគ្គិសនីវៀតណាមនឹងធ្វើការសិក្សាលទ្ធភាពអនុវត្តន៍សម្រាប់គម្រោងសេសានក្រោម ២ ដែលរួមមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមួយ និង ដាក់ជូនរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ

ជូនក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល។ អគ្គិសនីវៀតណាមក៏នឹងបង្កើតក្រុមហ៊ុនមួយផងដែរស្របតាមច្បាប់កម្ពុជា ដែលមានឈ្មោះបណ្តោះអាសន្នហៅថា "ក្រុមហ៊ុនអគ្គិសនីសេសានក្រោម ២។" បន្ទាប់មក អគ្គិសនីវៀតណាមនឹងវិនិយោគលើគម្រោងតាមរយៈសាខារបស់ខ្លួនដែលមានមូលដ្ឋាននៅកម្ពុជា ក្រោយពេលបញ្ចប់ការសិក្សាលទ្ធភាពអនុវត្តន៍គម្រោង (និង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន) ក្នុងឆ្នាំ ២០០៩។ គម្រោងនេះត្រូវបានរំពឹងថានឹងត្រូវបានបញ្ចប់ក្នុងរយៈពេលបួនឆ្នាំ។

## ៣. យោបល់ទូទៅអំពីកិច្ចដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

គោលបំណងចម្បងនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង កិច្ចដំណើរការពិគ្រោះយោបល់សាធារណៈពាក់ព័ន្ធ គឺសំដៅជួយអ្នកធ្វើសេចក្តីសម្រេចចិត្តរាជរដ្ឋាភិបាលក្នុងការកំណត់ថាតើការវិនិយោគមួយលើ ហេដ្ឋារចនាសម្ព័ន្ធ (ដែលជាធម្មតាមានលក្ខណៈធំ) គឺដើម្បីផលប្រយោជន៍សាធារណៈឬទេ។ ការកំណត់ថាតើអ្វីទៅគឺជា "ផលប្រយោជន៍សាធារណៈ" គឺជាលំហាត់ដ៏សំខាន់និងច្រើនតែមានលក្ខណៈចម្រូងចម្រះមួយ ដែលទាមទារឱ្យមានធាតុចូលសាធារណៈទូលាយ ដោយសារជាធម្មតាផលប្រយោជន៍ជាច្រើនត្រូវបានរងផលប៉ះពាល់។ គោលការណ៍នាំមុខដ៏ប្រសើរមួយ គប្បីគឺជា "មិនធ្វើឱ្យមានអន្តរាយ។" ក្នុងន័យនេះ នៅទីណាដែលការវិនិយោគត្រូវបានរំពឹងថានឹងបណ្តាលឱ្យមានការខូចខាត អ្នកអភិវឌ្ឍគម្រោងត្រូវឬគប្បីត្រូវមានករណីយកិច្ចសម្រាលឬផ្តល់សំណងចំពោះការខូចខាតទាំងនេះ ចេញពីលំហូរប្រាក់ចំណេញ/ប្រាក់ចំណូលគម្រោង។ គម្រោងក៏ត្រូវតែត្រូវបានចាត់ទុកថាស្របច្បាប់ផងដែរ ដោយគម្រោងបំពេញតាមល័ក្ខខ័ណ្ឌ និងស្តង់ដារដែលមានចែងនៅក្នុងច្បាប់។ ឧទាហរណ៍ ស្របតាមច្បាប់ភូមិបាលកម្ពុជា ពុំមានបុគ្គលណាមួយអាចត្រូវបានគេបណ្តេញចេញពីដីរបស់ខ្លួនឡើយ លុះត្រាណាតែករណីនោះត្រូវបានចាត់ទុកថាដើម្បីផលប្រយោជន៍សាធារណៈ។ ច្បាប់នេះដាក់បន្ទុកលើអ្នកអភិវឌ្ឍគម្រោងសេសានក្រោម ២ និងតាមន័យទូលាយលើអ្នកពិគ្រោះការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង អាជ្ញាធរត្រួតពិនិត្យកម្ពុជា ឱ្យបង្ហាញថាគម្រោងបម្រុងអនុវត្តនេះបម្រើផលប្រយោជន៍សាធារណៈកម្ពុជា។ បើពុំដូច្នោះទេ ការរើលំនៅឋានរបស់ប្រជាពលរដ្ឋកម្ពុជាដើម្បីផ្តល់លទ្ធភាពឱ្យគម្រោងសេសានក្រោម ២ អាចត្រូវបានចាត់ទុកថាខុសច្បាប់ និងនាំទៅដល់ករណីបណ្តឹងតាមផ្លូវច្បាប់ប្រឆាំងម្ចាស់គម្រោង និងវិនិយោគិន។

ជាទូទៅ "ផលប្រយោជន៍សាធារណៈ" ពាក់ព័ន្ធនឹងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ត្រូវបានកំណត់ដោយប្រើការគួបផ្សំគ្នានៃការវិភាគថ្លៃចំណាយ-អត្ថប្រយោជន៍ ការវាយតម្លៃបរិស្ថាន និង យន្តការចូលរួម

សាធារណៈ។ ការត្រួតពិនិត្យរបស់រាជរដ្ឋាភិបាល គឺសំខាន់ក្រៃលែងដើម្បីធានាឱ្យបានថាកិច្ចដំណើរការទាំងមូលមានយុត្តិធម៌ បើកទូលាយចំពោះការចូលរួមសាធារណៈ មានតម្លាភាព និង មានភាពស្មោះត្រង់នៅក្នុងការវាយតម្លៃផ្នែកបច្ចេកទេស សេដ្ឋកិច្ច និង បរិស្ថានរបស់គម្រោង។ កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលអាចទុកចិត្តបានទទួលស្គាល់យ៉ាងច្បាស់លាស់ថាគេនឹងឃើញមានផលប្រយោជន៍ប្រជែងគ្នានិងច្រើនតែមានវិវាទ ដែលរងផលប៉ះពាល់ពីគម្រោង ប៉ុន្តែ ការសម្រេចចិត្តស្ថាពរត្រូវតែផ្អែកលើការគោរពសិទ្ធិរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ច្រើនជាងគេ និង វិធាននៃច្បាប់។ ជាថ្មីម្តងទៀត គោលការណ៍ "មិនធ្វើឱ្យមានអន្តរាយ" គប្បីជានិច្ចកាលដឹកនាំអ្នកធ្វើសេចក្តីសម្រេចចិត្តនៅក្នុងការវាយតម្លៃលើការវិនិយោគដែលបានស្នើឡើង។

អ្នកអភិវឌ្ឍគម្រោងសេសានក្រោម ២ អាចយល់ឃើញថាកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគឺជាការងារដែលត្រូវចំណាយច្រើននិងលំបាកដែលត្រូវបានកំណត់ដោយបង្ខំលើពួកគេ ជាពិសេស ខណៈដែលការអភិវឌ្ឍន៍វារីអគ្គិសនីគឺជាអាទិភាពចម្បងរួចទៅហើយសម្រាប់រាជរដ្ឋាភិបាលកម្ពុជា និង ខណៈដែលតម្រូវការអគ្គិសនីនៅប្រទេសកម្ពុជានិងប្រទេសវៀតណាមមានលក្ខណៈលើសពីការផ្គត់ផ្គង់ដែលមាន។ ពួកគេអាចអះអាងថាការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ខ្លួនបំពេញតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន និង ថាដល់ពេលហើយដែលរាជរដ្ឋាភិបាលកម្ពុជាគប្បីចេញអាជ្ញាប័ណ្ណមួយដែលអនុញ្ញាតដល់ការស្ថាបនាទំនប់សេសានក្រោម ២ ដោយគ្មានការអូសបន្លាយពេលថែមទៀត។

ប៉ុន្តែ អ្វីដែលគួរគិតគូរនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តគោលនយោបាយសាធារណៈ គឺមិនមែនគឺជាអ្វីដែលអ្នកអភិវឌ្ឍគម្រោងយល់ថាជាសិទ្ធិរបស់ខ្លួននោះទេ ប៉ុន្តែ គឺជាប្រការដែលថាតើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់អ្នកអភិវឌ្ឍប្រឡងជាប់ការធ្វើតេស្តនៃការពិនិត្យពិច័យនិងភាពទទួលយកបាននៃសាធារណជនឬទេ។ តើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានបានបំពេញចិត្តប្រជាជនដែលអាយុជីវិតនិងអនាគតរបស់ខ្លួនត្រូវបានគម្រាមកំហែងដោយផ្ទាល់ដោយគម្រោងឬទេ? ឬមួយក៏មានសំណួរនិងការបារម្ភដែលមិនទាន់បានដោះស្រាយហើយអំពីផលប៉ះពាល់នៃគម្រោង ការគ្រោងដំណើរការ ក៏ដូចជា វិធានការសម្រាលផលប៉ះពាល់និងសំណង និង កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាទូទៅផងដែរ? គឺនៅក្នុងបរិបទនេះហើយដែលការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងសេសានក្រោម ២ ត្រូវតែត្រូវបានវិនិច្ឆ័យ។

អាជ្ញាធរកម្ពុជានឹងយល់ឃើញថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងសេសានក្រោម ២ បានខ្វះភាពទុកចិត្តបានជាសាធារណៈចាប់តាំងពីពេលចាប់ផ្តើម ដោយសារការខកខានរបស់អគ្គិសនីវៀតណាមមិនបានសង

និង/ឬសម្រាលការខូចខាតដែលត្រូវបានបណ្តាលឱ្យកើតឡើងនៅក្នុងបូរណភាពដែនដីកម្ពុជា ដោយប្រតិបត្តិការវារីអគ្គិសនីនៃអគ្គិសនីវៀតណាមនៅលើទន្លេសេសាននិងទន្លេស្រែពកផ្នែកលើនៅក្នុងប្រទេសវៀតណាម។ ប្រជាជនកម្ពុជា ដែលត្រូវរងអន្តរាយដោយទំនប់ជាកម្មសិទ្ធិរបស់អគ្គិសនីវៀតណាម បានរង់ចាំសំណងនិងវិធានការសម្រាលផលប៉ះពាល់អស់ពេលជាងមួយទសវត្សរ៍ហើយ និង នៅតែកំពុងរង់ចាំ។

នៅក្នុងបរិបទនៃការខកខានកន្លងមកនេះហើយ ដែលការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងសេសានក្រោម ២ ត្រូវតែត្រូវបានវិនិច្ឆ័យដោយប្រជាពលរដ្ឋ អាជ្ញាធររាជរដ្ឋាភិបាល និង តំណាងរាជរដ្ឋាភិបាល តាមអាណត្តិជាប់ឆ្នោតកម្ពុជា មុនពេលដែលការយល់ព្រមបន្ថែមទៀតណាមួយត្រូវបានផ្តល់ជូនអ្នកអភិវឌ្ឍ។

## ៤. យោបល់ជាក់លាក់និងអនុសាសន៍

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានពិនិត្យមើលឡើងវិញលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) សម្រាប់គម្រោងវារីអគ្គិសនីសេសានក្រោម ២ នៅខេត្តស្ទឹងត្រែង ដែលត្រូវបានរៀបចំដោយក្រុមហ៊ុន Key Consultants Cambodia (KCC) ជូនក្រុមហ៊ុន Power Engineering Consulting Joint Stock Company 1 (PECC1) ដែលមានមូលដ្ឋាននៅក្រុងហាណូយ កាលពីខែ តុលា ឆ្នាំ ២០០៨។ ផ្អែកលើការពិនិត្យមើលឡើងវិញរបស់យើងលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង ចំណេះដឹងអំពីស្តង់ដារនិងការអនុវត្តន៍ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅប្រទេសកម្ពុជា បណ្តាប្រទេសជិតខាងជាប់ទន្លេមេគង្គ និង អន្តរជាតិ យើងខ្ញុំសូមដាក់ជូននូវយោបល់និងអនុសាសន៍ជាក់លាក់ខាងក្រោមនេះ:

- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ មិនបានផ្តល់ភស្តុតាងពេញលេញថាគម្រោងអាចផ្គត់ផ្គង់អគ្គិសនីដោយចំណេញក្នុងអត្រាតម្លៃទាបជាងគូប្រកួតប្រជែងរបស់ខ្លួន ដោយសារព័ត៌មានមិនគ្រប់គ្រាន់អំពីថ្លៃចំណាយនិង ហានិភ័យនៃគម្រោង។
- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ខកខានមិនបានគោរពតាមសេចក្តីព្រាងគោលការណ៍ណែនាំការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចំណុចទី ៦ និង ១០ ដូចដែលត្រូវបានកំណត់ដោយក្រសួងបរិស្ថានកម្ពុជា។
- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ខកខានមិនបានបង្ហាញក្របខ័ណ្ឌគោលនយោបាយ ឬ ស្ថាប័ន ឬ បទប្បញ្ញត្តិ ដែលគាំទ្រការអះអាងរបស់អ្នកអភិវឌ្ឍដែលថាសំណងនិងវិធានការសម្រាលផលប៉ះពាល់នឹងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធិភាព។

- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ខកខានមិនបានដាក់បញ្ចូលការពិនិត្យមើលជម្រើសផ្គត់ផ្គង់ថាមពលដែលមានលក្ខណៈខូចខាតតិចជាង ។
- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ មិនបានផ្តល់ភស្តុតាងដែលថាអាជ្ញាធរកម្ពុជាបានត្រៀមលក្ខណៈគ្រប់គ្រាន់ដើម្បីអនុវត្តគម្រោងមួយដែលមានទំហំប៉ុននេះដោយគ្មានជនរងគ្រោះឬការខូចខាតគ្មានសំណង ។
- សមាមាត្រអត្ថប្រយោជន៍/ថ្លៃចំណាយសម្រាប់គម្រោង ត្រូវបានបង្ហាញដោយគ្មានការពន្យល់ - ព័ត៌មាននេះត្រូវតែត្រូវបានបញ្ចេញជាលម្អិតសម្រាប់ការពិនិត្យមើលសាធារណៈ និង ការផ្ទៀងផ្ទាត់ឯករាជ្យ ។
- ពុំមានការធ្វើការពិគ្រោះយោបល់សាធារណៈហួសពីតំបន់ដែលត្រូវជន់លិចឬជន់លិចដោយអន្លើដោយសារគម្រោង។ ចំណុចនេះមើលរំលងប្រជាជនរងផលប៉ះពាល់ពីគម្រោងរាប់ពាន់នាក់ នៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។
- ផែនការសម្រាលផលប៉ះពាល់និងការប៉ាន់ស្មានចំណាយ មិនត្រូវបានផ្សព្វផ្សាយ និង ផ្ទៀងផ្ទាត់ដោយប្រជាជននៅតាមគ្រប់តំបន់រងផលប៉ះពាល់ពីទំនប់ទាំងអស់ឡើយ ។
- ក្រសួងបរិស្ថាន និង អាជ្ញាធរអគ្គិសនីកម្ពុជា (EAC) គប្បីផ្អាកការយល់ព្រមថែមទៀត ទាំងអស់សម្រាប់គម្រោងសេសានក្រោម ២ រហូតដល់ពេលដែលការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ត្រូវបានកែសម្រួលឡើងវិញ និង ត្រូវបានយល់ព្រមនៅតាមគ្រប់តំបន់រងផលប៉ះពាល់ពីគម្រោងទាំងអស់ នៅក្នុងប្រទេសកម្ពុជា ។

ការងារបន្ថែមលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង ការពិគ្រោះយោបល់សាធារណៈ យ៉ាងហោចណាស់គប្បីរួមមានៈ

- កិច្ចដំណើរការពិគ្រោះយោបល់សាធារណៈមួយ ដែលសំដៅរាប់បញ្ចូលតំបន់រងផលប៉ះពាល់ពីគម្រោងទាំងអស់នៅក្នុងប្រទេសកម្ពុជា រួមមានភាពជាតំណាងមកពីអ្នកប្រើប្រាស់/អ្នកបង់ប្រាក់អគ្គិសនី អ្នកផ្គត់ផ្គង់ថាមពលប្រកួតប្រជែង និង មុខសញ្ញាវិនិយោគិនលើជម្រើសប្រកួតប្រជែងផ្សេងៗ ។
- សេចក្តីព្រាងក្របខ័ណ្ឌកិច្ចសន្យាមួយដែលចែងពីស្តង់ដារនិងនីតិវិធីផ្តល់សំណងសម្រាប់ទូទាត់ បណ្តឹងសារទុក្ខ ។ល ។
- ផែនការលម្អិតមួយសម្រាប់ការអនុវត្តន៍ដែលបង្ហាញលំដាប់ខ្សែនៃយន្តការគណនេយ្យភាព ប្រតិបត្តិ និង អនុលោមភាព និង

- ក្របខ័ណ្ឌគោលនយោបាយនិងបទប្បញ្ញត្តិមួយដែលគ្រប់គ្រងក្រុមហ៊ុនវៀតណាមដែលនឹងទទួលខុសត្រូវលើការសាងសង់និងប្រតិបត្តិការគម្រោងសេសានក្រោម ២ នៅក្នុងអំឡុងពេលនៃកិច្ចសន្យាសាងសង់-ប្រតិបត្តិការ-ផ្ទេរ (BOT) ។

## ៥. ចំណុចខ្វះខាតសំខាន់ៗនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

នៅក្នុងជំពូកនេះ យើងពិនិត្យមើលកាន់តែលម្អិតថែមទៀតលើចំណុចខ្វះខាតសំខាន់ៗមួយចំនួននៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងសេសានក្រោម ២ ដូចខាងក្រោមនេះ:

- **ការពិគ្រោះយោបល់សាធារណៈមិនពេញលេញ**
- ការធ្វើតេស្តប្រកបដោយសុពលភាពតែមួយគត់លើភាពអាចទុកចិត្តបាននៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺតាមរយៈការពិគ្រោះយោបល់សាធារណៈ។ ការវាយតម្លៃផលប៉ះពាល់បរិស្ថានដោយគ្មានការពិគ្រោះយោបល់សាធារណៈ គឺជាការងារគ្មានន័យមួយ។ ក្នុងករណីនេះ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងសេសានក្រោម ២ ប៉ាន់ស្មានថាប្រជាជនប្រមាណជា ៣០.០០០ នាក់ដែលរស់នៅខ្សែទឹកខាងក្រោម នឹងត្រូវរងផលប៉ះពាល់ជាអវិជ្ជមានដោយការសាងសង់និងប្រតិបត្តិការនៃគម្រោងទំនប់សេសានក្រោម២ និង ប្រជាជនរាប់ម៉ឺននាក់ទៀតនៅខ្សែទឹកខាងក្រោម។ ប៉ុន្តែ មានប្រជាជនតែពីរបីរយនាក់ប៉ុណ្ណោះដែលត្រូវបានពិគ្រោះយោបល់ និង ពុំមានការរៀបចំជាឯកសារឱ្យបានត្រឹមត្រូវឡើយ។ ទោះបីជាតាមស្តង់ដារអ្វីក៏ដោយ ចំណុចនេះគឺមិនអាចទទួលយកបានទេ។ គម្រោងសេសានក្រោម២ នឹងជនលិចផ្ទៃដីជាង ៣០០ គីឡូម៉ែត្រការ៉េ ដែលប៉ះពាល់ភូមិរាប់សិបនៅតាមតំបន់ជាប់ទន្លេសេសានិងទន្លេស្រែពក និងហួសពីនោះទៅដល់ទន្លេសាបនិងដីសណ្តរទន្លេមេគង្គ។ បើគ្មានធាតុចូលលម្អិតពីប្រជាជនរងផលប៉ះពាល់ និងតំណាងតាមអាណត្តិជាប់ឆ្នោតនៅតាមតំបន់រងផលប៉ះពាល់ទេ នោះអ្នកអភិវឌ្ឍគម្រោងមិនអាចរៀបចំវិធានការសម្រាលផលប៉ះពាល់និងសំណងឱ្យបានពេញលេញឡើយ។ ដូចគ្នានេះដែរ ពួកគេមិនអាចបង្ហាញការវាយតម្លៃដ៏ប្រាកដប្រជាលើហានិភ័យនិងថ្លៃចំណាយនៃគម្រោងជូនដល់មុខសញ្ញាវិនិយោគិន និងអ្នកបង់ប្រាក់អគ្គិសនី។ អ្នកពិគ្រោះការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថានហាក់បីដូចជាចាត់ទុកថាការពិគ្រោះយោបល់សាធារណៈគឺជាការងារធ្វើតែមួយដង ដើម្បីគោរពតាមគោលការណ៍ណែនាំស្តីពីការវាយតម្លៃ

ហេតុប៉ះពាល់បរិស្ថាន នៅពេលដែលការពិគ្រោះយោបល់សាធារណៈគប្បីត្រូវបានដាក់បញ្ចូលជាផ្នែកអចិន្ត្រៃយ៍មួយនៃគម្រោងវិនិយោគដែលមានទំហំធំដូច្នេះ។

- **ពុំមានការពិនិត្យមើលជម្រើសផ្គត់ផ្គង់អគ្គិសនីផ្សេងទៀត**

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ខកខានមិនបានផ្តល់ការប្រៀបធៀបនិងការពិនិត្យមើលជម្រើសផ្គត់ផ្គង់អគ្គិសនីប្រកួតប្រជែងផ្សេងទៀតដែលអាចផ្តល់បរិមាណស្មើគ្នាមួយនៃសមត្ថភាពផលិតអគ្គិសនីអាចទុកចិត្តបាននៅក្នុងរយៈពេលបួនឆ្នាំខាងមុខ។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ច្រើនតែសន្មតថា ដោយសារការអភិវឌ្ឍន៍វារីអគ្គិសនីគឺជាអាទិភាពកំពូលមួយសម្រាប់រាជរដ្ឋាភិបាលកម្ពុជា អ្នកអភិវឌ្ឍគម្រោងសេសានក្រោម២ មិនចាំបាច់ "ប្រកួតប្រជែង" ជាមួយអ្នកដែលអាចផ្គត់ផ្គង់ផ្សេងទៀតទេសម្រាប់ផ្តល់សេវាជូនដល់អ្នកបង់ប្រាក់កម្ពុជា ឬថាពុំចាំបាច់សួរសំណួរអ្វីអំពីការចង់បានគម្រោង និង វិភាគទានរួមរបស់វាចំពោះសេដ្ឋកិច្ចកម្ពុជាឡើយប្រៀបធៀបទៅនឹងជម្រើសផ្សេងទៀត។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ប៉ាន់ស្មានថាថ្លៃចំណាយលើការតាំងលំនៅឋានថ្មីនិងសំណងសម្រាប់គម្រោងសេសានក្រោម២ នឹងមានតម្លៃជាង ៥០ លានដុល្លារអាមេរិក។ មូលធនចំនួនប៉ុណ្ណោះអាចជាម៉ាស៊ីនផលិតអគ្គិសនីកម្លាំង ៥០-ម៉េហ្គាវ៉ាត់មួយ ដែលអាចត្រូវបានតម្លើងនិងដំណើរការបានក្នុងរយៈពេលតែប៉ុន្មានខែប៉ុណ្ណោះ និង ដើរដោយឥន្ធនៈមួយចំនួនដែលអាចរកទិញបាន យ៉ាងហោចណាស់រហូតដល់ពេលដែលប្រទេសកម្ពុជាអាចយកឧស្ម័នធម្មជាតិរបស់ខ្លួនមកប្រើប្រាស់បាន និង បញ្ចប់គម្រោងវារីអគ្គិសនីរបស់ខ្លួនដែលស្ថិតក្នុងការសាងសង់រួចហើយ។ មុនពេលដែលរាជរដ្ឋាភិបាលកម្ពុជាដាក់ឱ្យអ្នកបង់ប្រាក់អគ្គិសនីទទួលយកទំនប់សេសានក្រោម២ ដែលមានតម្លៃ ៨១៦ លានដុល្លារ ពួកគេមានសិទ្ធិត្រូវដឹងថា តើពួកគេមានជម្រើសអ្វីខ្លះ រួមទាំងការគួបផ្សំនៃរោងចក្រវារីអគ្គិសនីខ្នាតតូចជាង រោងចក្រអគ្គិសនីប្រើថាមពលព្រះអាទិត្យ និង រោងចក្រអគ្គិសនីប្រើឧស្ម័ន។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ខកខានមិនបានផ្តល់ព័ត៌មាននេះ។

ថ្វីបើសេចក្តីព្រាងគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថានមិនតម្រូវឱ្យមានការពិនិត្យមើលជម្រើសនានាដូចនេះក្តី ក៏ការប្រៀបធៀបតម្លៃនិងអត្ថប្រយោជន៍គម្រោងជាមួយជម្រើសផ្គត់ផ្គង់ថាមពលផ្សេងទៀត គឺសំខាន់ក្រៃលែងដើម្បីកំណត់ថាតើគម្រោងសេសានក្រោម២ បម្រើ "ផលប្រយោជន៍សាធារណៈ" ឬទេ។ ចំពោះមុខតម្រូវការមូលធនប្លែកពីធម្មតា និង ការខូចខាតបរិស្ថានដ៏សន្ធឹកសន្ធាប់សម្រាប់ការផលិតថាមពលអាចទុកចិត្តបានកម្លាំងត្រឹមតែ ១០០ ម៉េហ្គាវ៉ាត់ ប្រជាជនកម្ពុជាគប្បីដឹងថាតើខ្លួនមានជម្រើសអ្វីខ្លះ។

ប្រសិនបើក្រសួងបរិស្ថាន មិនតម្រូវឱ្យមានការពិនិត្យមើលបែបនេះមួយទេ នោះវាគឺស្ថិតនៅក្នុងអាណត្តិរបស់អាជ្ញាធរអគ្គិសនីកម្ពុជាដែលត្រូវផ្តួចផ្តើមការប្រៀបធៀបនិងការពិនិត្យមើលបែបនេះ ជាផ្នែកមួយនៃនីតិវិធីមុនពេលផ្តល់អាជ្ញាប័ណ្ណ។ ទាំងក្រសួងបរិស្ថាន ទាំងអាជ្ញាធរអគ្គិសនីកម្ពុជាមានសមត្ថកិច្ចបដិសេធសំណើគម្រោងតាមផែនការថាមិនអាចដំណើរការបាន/មិនអាចអនុវត្តបាន និង លើកទឹកចិត្តឱ្យអ្នកអភិវឌ្ឍគម្រោងស្វែងរកជម្រើសផ្សេងទៀតដែលមានលក្ខណៈអនុវត្តបានផ្នែកសេដ្ឋកិច្ចនិងខូចខាតបរិស្ថានតិចជាង។

- **ព័ត៌មានមិនគ្រប់គ្រាន់អំពីថ្លៃចំណាយលើការសម្រាលផលប៉ះពាល់**

ផ្នែកដ៏សំខាន់បំផុតមួយនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន - ការប៉ាន់ស្មានថ្លៃចំណាយសម្រាប់ការតាំងលំនៅឋានថ្មី សំណង និង ការសម្រាលផលប៉ះពាល់ ត្រូវបានបង្កប់នៅខាងចុងរបាយការណ៍នៅក្នុងឧបសម្ព័ន្ធ ៦ និង ត្រូវបានដាក់ឈ្មោះខុសជា "ការប៉ាន់ស្មានថ្លៃចំណាយសម្រាប់ការសម្រាលផលប៉ះពាល់និងការឃ្លាំមើលបរិស្ថាន។" ការប៉ាន់ស្មានថ្លៃចំណាយទំហំបួនទំព័រនេះ មិនដាក់បញ្ចូលការពន្យល់តាមខ្ទង់និងការរាយមុខចំណាយទេ ដែលគប្បីត្រូវបានផ្សព្វផ្សាយសម្រាប់ការពិនិត្យមើលសាធារណៈ។ បើគ្មានព័ត៌មាននេះទេ លទ្ធភាពផ្នែកសេដ្ឋកិច្ចឬការចង់បានគម្រោងមិនអាចផ្ទៀងផ្ទាត់បានទេ។

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដាក់បញ្ចូលការប៉ាន់ស្មានថ្លៃចំណាយរបស់ក្រុមហ៊ុន KCC សម្រាប់សម្រាលផលប៉ះពាល់អវិជ្ជមាន ជាទឹកប្រាក់ ១២៧ លានដុល្លារអាមេរិក។ របាយការណ៍នេះក៏ដាក់បញ្ចូលផងដែរនូវការប៉ាន់ស្មានមួយពីប្រទេសវៀតណាមផ្អែកលើគម្រោងវារីអគ្គិសនីកន្លងមក ជាទឹកប្រាក់ ៧៨ លានដុល្លារអាមេរិក។ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ មិនពន្យល់ថាតើការប៉ាន់ស្មានណាមួយត្រូវបានប្រើនៅក្នុងការវិភាគអត្ថប្រយោជន៍-ថ្លៃចំណាយ ឬ ដាក់បញ្ចូលទៅក្នុងតម្លៃវិនិយោគសរុបឡើយ។

- **ពុំមានក្របខ័ណ្ឌកិច្ចសន្យាសាងសង់-ដំណើរការ-ផ្ទេរ (BOT) សម្រាប់ការបែងចែកថ្លៃចំណាយ ហានិភ័យ ប្រាក់ចំណូល និង ការទទួលខុសត្រូវនៅក្នុងចំណោមភាគីពាក់ព័ន្ធឡើយ។**

ឯកសារសំខាន់បំផុតសម្រាប់មុខសញ្ញាវិនិយោគិនលើគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំប្រភេទនេះ ដែលមានផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរនិងរយៈពេលវែង គឺជាឯកសារទាំងឡាយដែលរៀបរាប់ពីកិច្ចព្រមព្រៀងកិច្ចសន្យារវាងម្ចាស់គម្រោង រាជរដ្ឋាភិបាលកម្ពុជា និង ភាគីរងផលប៉ះពាល់ផ្សេងទៀត។ ជាធម្មតា ឯកសារទាំងនេះផ្តល់ព័ត៌មានលម្អិតអំពីការបែងចែកការទទួលខុសត្រូវ ភាពទទួលខុសត្រូវខាងបរិស្ថាន ហានិភ័យ និង ប្រាក់ចំណូល។ ការពិនិត្យ

មើលសាធារណៈពេញលេញលើឯកសារកិច្ចសន្យាសាងសង់-ដំណើរការ-ផ្ទេរ (BOT) នៃគម្រោងសេសានក្រោម ២ គឺចាំបាច់មុនពេលផ្តល់ការយល់ព្រមឱ្យកសាងនិងដំណើរការ។ ចំណុចនេះគួរត្រូវបានដាក់បញ្ចូលនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់ការពិនិត្យមើលសាធារណៈនៅក្នុងដំណាក់កាលដំបូងបំផុតនៃការវាយតម្លៃគម្រោង។ ក្រសួងបរិស្ថាន និង អាជ្ញាធរអគ្គិសនីកម្ពុជា គប្បីចាត់ចែងរួមគ្នានូវការពិនិត្យដ៏ពេញលេញបែបនេះមួយមុនពេលធ្វើការព្រមព្រៀងបន្ថែមទៀតណាមួយជាមួយអ្នកអភិវឌ្ឍគម្រោងនៅប្រទេសវៀតណាម។ សំណួរគឺថាតើកិច្ចព្រមព្រៀងនេះគឺជាកិច្ចព្រមព្រៀងមួយល្អសម្រាប់ប្រជាជនកម្ពុជានៅភូមិភាគឦសានឬទេ ហើយប្រទេសកម្ពុជាទាំងមូលគប្បីត្រូវបានពិនិត្យមើលដោយយ៉ាងមធ្យ័តនិងស្មោះត្រង់ដោយប្រជាជនកម្ពុជាដើម្បីប្រជាជនកម្ពុជា។

- **លទ្ធភាពសេដ្ឋកិច្ចមិនមានភស្តុតាងច្បាស់លាស់ / តម្លៃចំណាយមានលក្ខណៈអាចចោទសួរបាននៅក្នុងថវិកាគម្រោង**

មូលហេតុសេដ្ឋកិច្ចរបស់អ្នកអភិវឌ្ឍសម្រាប់វិនិយោគជាង ៨០០ លានដុល្លារអាមេរិកលើគម្រោងថាមពលតែមួយ មិនត្រូវបានពន្យល់ឱ្យបានគ្រប់គ្រាន់ទេ។ ថ្លៃចំណាយខ្លះ ដូចជា ៣០ លានដុល្លារអាមេរិកសម្រាប់ការដាំព្រៃឈើឡើងវិញ និង បរិមាណប្រាក់មិនបញ្ចេញចំនួនមួយសម្រាប់សងម្ចាស់សម្បទានព្រៃឈើនៅក្នុងតំបន់គម្រោង ក៏ដូចជាអត្ថប្រយោជន៍រំពឹងសម្រាប់ប្រទេសកម្ពុជា នៅតែគឺជាសំណួរសំខាន់មួយ។ គេមិនដឹងច្បាស់ទេថាហេតុអ្វីបានជាការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដាក់បញ្ចូលថវិកាចំនួន ៥.៣២៥.០០០ ដុល្លារសម្រាប់បោសសម្អាតមីន ខណៈដែលមិនមានវត្តមានដែលគេដឹងនៃគ្រឿងផ្ទុះនិងគ្រាប់បែកនៅក្នុងតំបន់គម្រោង។ ចូរកត់សម្គាល់ថាប្រជាជនកម្ពុជាសាមញ្ញនឹងត្រូវបានរំពឹងថាត្រូវបង់ប្រាក់សម្រាប់ថ្លៃចំណាយទាំងនេះ និង មានសិទ្ធិត្រូវដឹងថាតើថវិកានេះគឺសម្រាប់អ្វីខ្លះ និងថាតើថវិកានេះគឺសមរម្យឬទេ។

- **ពុំមានក្របខ័ណ្ឌបទបញ្ញត្តិដើម្បីធានាឱ្យបានថាសិទ្ធិរបស់ប្រជាពលរដ្ឋត្រូវបានការពារឡើយ**

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ខកខានមិនបានដាក់បញ្ចូលក្របខ័ណ្ឌបទបញ្ញត្តិមួយដើម្បីធានាឱ្យបានថាសិទ្ធិរបស់ប្រជាជនរងផលប៉ះពាល់ត្រូវបានការពារ។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះផ្តល់នូវបញ្ជីមួយនៃច្បាប់របស់ប្រទេស ប៉ុន្តែ ខកខានមិនបានលើកឡើងថាតើម្ចាស់គម្រោងនឹងត្រូវបានចាប់ឱ្យទទួលខុសត្រូវយ៉ាងដូចម្តេចស្របតាមច្បាប់ទាំងនេះ និង ថាតើតាមរយៈយន្តការអ្វីដែលប្រជាពលរដ្ឋត្រូវស្វែងរកសំណងសម្រាប់ការខូចខាតមិនទាន់បានសង។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះពឹងផ្អែកតែលើសេចក្តីថ្លែងពីគោលបំណងប៉ុណ្ណោះ ឧទាហរណ៍

អាជ្ញាធរមានសមត្ថកិច្ចនឹងធានាឱ្យបានថា "គឺត្រឹមត្រូវនិងត្រូវបានទទួលយកដោយប្រជាជនរងផលប៉ះពាល់។" ច្បាស់ណាស់ ចំណុចនេះគឺមិនគ្រប់គ្រាន់ទេៈ យន្តការបទបញ្ញត្តិគឺចាំបាច់ដើម្បីទប់ស្កាត់អំពើពុករលួយនិងការបំពាន ផ្សេងទៀត និង ដើម្បីដាក់បញ្ចូលគណនេយ្យភាពទៅក្នុងគម្រោងនៅក្នុងគ្រប់ដំណាក់កាល។

- **ពុំមានភស្តុតាងថាម្ចាស់គម្រោង និង អាជ្ញាធររដ្ឋាភិបាលមានសមត្ថភាពដើម្បីអនុវត្តគម្រោងទំនប់សេសានក្រោម២ ដោយគ្មានការខូចខាតច្រើនចំពោះសុខភាព ទ្រព្យសម្បត្តិ ជីវភាព និង អនាគតសេដ្ឋកិច្ចរបស់ប្រជាជនច្រើនរាប់មិនអស់នៅភូមិភាគឦសាននៃប្រទេសកម្ពុជា។**

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចង្អុលបង្ហាញយ៉ាងច្បាស់ថានឹងមានផលវិបាកអវិជ្ជមានធ្ងន់ធ្ងរ និងរយៈពេលវែងចំពោះភូមិភាគឦសាននៃប្រទេសកម្ពុជានិងប្រជាជនរាប់ម៉ឺននាក់ ប្រសិនបើគម្រោងត្រូវបានអនុវត្តតាមផែនការ។ ប៉ុន្តែ គេពុំឃើញមានការលើកឡើងនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះទេថាតើអាជ្ញាធរមូលដ្ឋានឬអាជ្ញាធរថ្នាក់ជាតិនឹងត្រៀមលក្ខណៈដើម្បីដោះស្រាយបញ្ហាគ្មានព្រាងទុកនានាឬទេៈ គ្រប់មុខចាប់តាំងពីវិវាទដណ្តើមធនធាន និង សម្ពាធនៃការតាំងលំនៅឋានថ្មី រហូតដល់ជម្ងឺដម្កាត់ទាក់ទិននឹងគុណភាពទឹក កង្វះអាហារូបត្ថម្ភ និង ការបាត់បង់ជាអចិន្ត្រៃយ៍នៃមុខរបរកសិកម្មនិងនេសាទ។ មកដល់ពេលនេះ នៅពេលជួបប្រទះនឹងបញ្ហាទឹកជំនន់នៅក្នុងខេត្តស្ទឹងត្រែង មន្ត្រីទាំងឡាយគ្រាន់តែប្រកាសភាពអាសន្ន និង អំពាវនាវសុំជំនួយប៉ុណ្ណោះ ដូចដែលបានកើតឡើងនៅដើមខែ សីហា នៅពេលដែលទំនប់វារីអគ្គិសនីបានបើកទ្វារ ទឹកជំនន់របស់ខ្លួននៅក្នុងខេត្តជិតខាងអាតាពឺ (Attapue) (កាសែតឌឺខែមបូឌាដេលី ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០៩)។

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះពុំមានផ្តល់ភស្តុតាងអ្វីដើម្បីបង្ហាញថាតើអាជ្ញាធរកម្ពុជានឹងត្រៀមលក្ខណៈគ្រប់គ្រាន់យ៉ាងដូចម្តេចដើម្បីគ្រប់គ្រងគម្រោងមួយដែលមានផលប៉ះពាល់ច្រើនមុខនិងរយៈពេលវែងលើសុខភាពសាធារណៈ ភាពក្រីក្រ និង អនាគតសេដ្ឋកិច្ចនៃភូមិភាគឦសាននៃប្រទេសកម្ពុជា។ ការសន្មតដែលថាម្ចាស់គម្រោងនឹងទទួលខុសត្រូវ គឺមិនមានលក្ខណៈប្រាកដនិយមឡើយ។ អគ្គិសនីវៀតណាមនិងអាជ្ញាធរវៀតណាមបានធ្វើតិចតួចឬមិនបានធ្វើអ្វីទាំងអស់ ដើម្បីជួយប្រទេសកម្ពុជាក្នុងការដោះស្រាយផលប៉ះពាល់អវិជ្ជមានដែលបណ្តាលមកពីប្រតិបត្តិការវារីអគ្គិសនីនៅលើដែនទន្លេមេគង្គរួមនៅក្នុងទសវត្សរ៍កន្លងមកនេះ។ ហេតុដូច្នេះ ការទទួលខុសត្រូវនេះនឹងធ្លាក់ជាស្វ័យប្រវត្តិលើអាជ្ញាធរកម្ពុជា។ គេពុំឃើញមានចំណុចណាមួយនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះដែលបង្ហាញថាអាជ្ញាធរបានត្រៀមលក្ខណៈដើម្បី គ្រប់គ្រងផលប៉ះពាល់អវិជ្ជមានបានល្អជាង

កាលពីពេលមុននៅពេលដែលទំនប់វារីអគ្គិសនីខ្នាតធំទីមួយត្រូវបានសាងសង់លើទន្លេសេសាននៅខាងវៀតណាម កាលពីឆ្នាំ ១៩៩៦។ ប្រជាជនដែលរងផលប៉ះពាល់ដោយទំនប់នោះនៅមិនទាន់បានទទួលជំនួយ ឬ សំណងអ្វីពីអាជ្ញាធរនៅសងខាងព្រំដែនឡើយ។ នៅពេលដែលប្រជាជនទាំងនេះ ត្អូញត្អែរអំពីផលប៉ះពាល់ទាក់ទិននឹងទំនប់ ចម្លើយមានតាំងពីអសមត្ថភាពក្នុងការធ្វើតេស្តគុណភាពទឹក រហូតដល់ការសន្យាក្លែងក្លាយអំពីសកម្មភាព ដែលនៅក្រោយពេលនោះ គេឃើញមានតែភាពស្ងៀមស្ងាត់និងភាពគ្មានសកម្មភាព។

ប្រសិនបើក្រសួងបរិស្ថាននិងសហភាគីរបស់ខ្លួនដែលគឺជាសមាសភាពនៃគណៈកម្មាធិការតាំងលំនៅឋានថ្មី ពិតជាមានភារកិច្ចការពារផលប្រយោជន៍ចំពោះមុខនិងរយៈពេលវែងរបស់ប្រជាជនកម្ពុជា និង ធនធានបរិស្ថានដែលពួកគេពឹងអាស្រ័យលើពិតមែន ពោលគឺមិនមែនផលប្រយោជន៍របស់អ្នកអភិវឌ្ឍគម្រោងទេ នោះពួកគេគប្បីទាមទារឱ្យមានការត្រៀមលក្ខណៈប្រកបដោយគុណភាពខ្ពស់មួយសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំមួយ ដែលចាប់ផ្តើមចេញពីការវាយតម្លៃលើថ្លៃចំណាយគម្រោងឱ្យបានកាន់តែលម្អិតជាងនេះច្រើន ដោយសហការយ៉ាងជិតស្និតប្រជាជននិងតំបន់រងផលប៉ះពាល់។

## ៦. ការពិនិត្យមើលឡើងវិញនូវជំពូក ៦: ផលប៉ះពាល់បរិស្ថាន និង វិធានការកាត់បន្ថយផលប៉ះពាល់

នៅក្នុងជំពូកនេះ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (ដែលចាប់ពីពេលនេះ ត្រូវបានហៅថា "NGOF") ពិនិត្យមើលរបកគំហើញខ្លះៗនៃរបកគំហើញនៃការវាយតម្លៃហេតុប៉ះពាល់ បរិស្ថានស្តីពីផលប៉ះពាល់អវិជ្ជមានធំពាក់ព័ន្ធនឹងគម្រោងសេសានក្រោម២ និង អ្វីដែលអាចធ្វើបានឬមិនអាច ធ្វើបានចំពោះផលប៉ះពាល់ទាំងនេះ។ (របកគំហើញនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលត្រូវបានបង្ហាញជូនជា តួអក្សរទ្រេត គឺជាពាក្យដកស្រង់ដោយផ្ទាល់ ឬ ជាបរប្រយោគដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។)

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាៈ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះបង្ហាញថាមានការប៉ាន់ស្មានបីដោយឡែកពីគ្នានៃតម្លៃបរិស្ថានសម្រាប់គម្រោងសេសានក្រោម ២ - ការប៉ាន់ស្មានតម្លៃមួយដោយក្រុមហ៊ុន PECC1, ការប៉ាន់ស្មានតម្លៃមួយដោយក្រុមហ៊ុន KCC, និង ការប៉ាន់ស្មានតម្លៃមួយផ្អែកលើការអនុវត្តបច្ចុប្បន្ននៅប្រទេសវៀតណាម។ កាប៉ាន់ស្មានតម្លៃទាំងនេះមិនត្រូវបានបង្ហាញលម្អិតទេនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ គេក៏មិនឃើញមានផងទេនូវការពន្យល់អំពីអត្ថប្រយោជន៍និងថ្លៃចំណាយអ្វីដែល

ត្រូវបានប្រើដើម្បីគណនាសមាមាត្រអត្ថប្រយោជន៍-ថ្លៃចំណាយនៃគម្រោង។ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះគ្រាន់តែបង្ហាញសមាមាត្រអត្ថប្រយោជន៍-ថ្លៃចំណាយពីកម្រិត ១,១១ ដល់ ១,២០ □ ចំណុចនេះមានន័យថា សម្រាប់រាល់ប្រាក់ ១០០ ដុល្លារដែលត្រូវបានវិនិយោគលើគម្រោង ប្រាក់ចំណេញនឹងមានចំនួនពី ១១ ដុល្លារ ដល់ ២០ ដុល្លារ។ ការវាយលម្អិតទាំងស្រុងនៃតួលេខដែលត្រូវបានប្រើដើម្បីឈានដល់សេចក្តីសន្និដ្ឋាននេះមិនមានបង្ហាញនៅក្នុងរបាយការណ៍ទេ។ ជាមួយព័ត៌មានថ្លៃចំណាយកាន់តែពេញលេញ និង អាស្រ័យលើការប៉ាន់ស្មានតម្លៃរបស់អ្នកណាដែលត្រូវបានប្រើ សមាមាត្រអត្ថប្រយោជន៍-ថ្លៃចំណាយអាចមានលក្ខណៈអវិជ្ជមានផងក៏មិនដឹង ដែលនៅក្នុងករណីនេះ គម្រោងនឹងមិនមានលក្ខណៈអនុវត្តបានខាងសេដ្ឋកិច្ចឡើយ។ វាគឺជាប្រការសំខាន់ដែលប្រជាជនកម្ពុជាត្រូវ បានផ្តល់ឱកាសឱ្យពិនិត្យមើលការវិភាគទាំងស្រុងរបស់អ្នកអភិវឌ្ឍអំពីអត្ថប្រយោជន៍ និងថ្លៃចំណាយ។ សេចក្តីសង្ខេប ដែលត្រូវបានបង្ហាញគឺជាមូលដ្ឋានមិនគ្រប់គ្រាន់មួយសម្រាប់ការពិនិត្យមើលនិងការធ្វើសេចក្តីសម្រេចចិត្តសាធារណៈ។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាៈ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ បង្ហាញថ្លៃចំណាយសរុបមួយសម្រាប់ការតាំងលំនៅឋានថ្មី និង ការសម្រាលផលប៉ះពាល់បរិស្ថានក្នុងទឹកប្រាក់ប្រមាណជា ១២៥ លានដុល្លារ។ ទឹកប្រាក់នេះគឺជាចំនួនមូលធនប្លែកពីធម្មតាមួយដែលគេត្រូវការសម្រាប់គ្រាន់តែសងការខូចខាតដែលបណ្តាលមកពីការសាងសង់និងការដំណើរការទំនប់។ វាគឺជាប្រការសំខាន់ដែលត្រូវយល់ថាចំណាយនេះនឹងមិនជម្រុញឱ្យមានកំណើនសេដ្ឋកិច្ចទេ ប៉ុន្តែ គ្រាន់តែប៉ុនប៉ងស្តារជីវភាពដោយគ្មានការធានាអត្ថប្រយោជន៍ជូនប្រជាជនរងផលប៉ះពាល់ទេ។ ប្រជាជនកម្ពុជាគប្បីគឺជាអ្នកសម្រេចចុងក្រោយអំពីគម្រោងនេះ ក្រោយពេលដែលថ្លៃចំណាយទាំងអស់ត្រូវបានបើកបង្ហាញ។ ការវិនិយោគលើអគ្គិសនីដែលមានថ្លៃចំណាយតិចជាងនិងមានផលិតភាពខ្ពស់ជាង គប្បីត្រូវបានស្វែងរកជាជម្រើសផ្សេងៗជំនួសគម្រោងសេសានក្រោម២។

## ជីធ្លីលិចទឹក និង វិវាទពាក់ព័ន្ធ

*ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានៈ ដីនៅជុំវិញគម្រោងមានលក្ខណៈរាបស្មើបង្គួរ ដែលជាហេតុធ្វើឱ្យតំបន់អាងទឹកបម្រុងមានលក្ខណៈធំមែនទែន។ ដើម្បីសម្រាលផលប៉ះពាល់បរិស្ថាននិងសង្គមធ្ងន់ធ្ងរ កម្ពស់ទំនប់គប្បីត្រូវកាត់បន្ថយជាអប្បបរមាតាមតាមដែលអាចធ្វើទៅបាន ...។ មូលហេតុនៃកម្ពស់អប្បបរមាចុងក្រោយនៃទំនប់ និង មូលហេតុអ្វីបានជាវាមិនអាចមានលក្ខណៈទាបជាង នឹងត្រូវបានផ្តល់ជូននិងផ្សព្វផ្សាយជាសាធារណៈ ...។ មាន*

*ជម្រើសទីតាំងទំនប់ចំនួនពីរ ហើយការប្រើទីតាំងណាមួយនៃទីតាំងទាំងពីរនេះនឹងបណ្តាលឱ្យមានផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ។*

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា: សំណួរថាតើផ្ទៃដីដ៏ធំនៅភូមិភាគឦសាននៃប្រទេសកម្ពុជា រួមទាំងផ្ទៃដីនៃតំបន់កំណត់ជាជម្រកសត្វព្រៃជាតិ គប្បីត្រូវវិពន្លិចទឹកដើម្បីគោលបំណងនៃការផលិតវារីអគ្គិសនីនៅខេត្តស្ទឹងត្រែង ឬទេនោះ គប្បីត្រូវបានពិភាក្សាជាចំហរ និង សម្រេចដោយតំណាងរាជរដ្ឋាភិបាលតាមអាណត្តិជាប់ឆ្នោតនៅថ្នាក់ស្រុក ខេត្ត និងជាតិ ក្នុងលក្ខណៈតម្លាភាពនិងប្រជាធិបតេយ្យពេញលេញ និង ដោយមានការគោរពសិទ្ធិរបស់ជនជាតិដើមភាគតិចដែលពឹងអាស្រ័យដោយផ្ទាល់លើដីនោះនិងធនធានពាក់ព័ន្ធ។ វាគឺជាប្រការមិនគ្រប់គ្រាន់ទេដែលការវាយតម្លៃ ហេតុប៉ះពាល់បរិស្ថានគ្រាន់តែសន្យាផ្តល់យុត្តិកម្មសាធារណៈមួយអំពីជម្រើសប្លង់ និងទីតាំងទំនប់របស់អ្នកអភិវឌ្ឍ។ ប្រជាជនកម្ពុជាត្រូវតែមានឱកាសសម្រេចថាតើគម្រោងនោះតាមការស្នើសុំ គប្បីត្រូវអនុវត្តឬទេ និងស្ថិតក្រោមស្ថានភាពនិងល័ក្ខខ័ណ្ឌអ្វីខ្លះ។ ម្យ៉ាងទៀត ពួកគេគប្បីមានឱកាសណែនាំឱ្យអ្នកអភិវឌ្ឍគម្រោងរិះរកមើលទីតាំងវារីអគ្គិសនីផ្សេងដែលមានលក្ខណៈខូចខាតតិចជាងនៅតាមតំបន់នានាដែលនៅទីនោះ ដីមិនសូវមានលក្ខណៈរាបស្មើ ហើយការខូចខាតបរិស្ថានទំនងជាមានលក្ខណៈតិចជាង។ យើងកត់សម្គាល់ថាគោលនយោបាយធនធានទឹកកម្ពុជាគាំទ្រការអភិវឌ្ឍន៍វារីអគ្គិសនីគ្រប់ទំហំទាំងអស់ មិនមែនគ្រាន់តែទំហំធំប៉ុណ្ណោះទេ ហើយជាពិសេស គម្រោងដែលជួយកាត់បន្ថយភាពក្រីក្រនៅតាមសហគមន៍មូលដ្ឋាន។ ជម្រើសទំហំផ្សេងៗនៃវារីអគ្គិសនី គប្បីត្រូវបានរិះរកមើល។

## តំបន់ថ្មីសម្រាប់ការតាំងលំនៅឋានថ្មី

*ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន: តំបន់ថ្មីសម្រាប់ការតាំងលំនៅឋានថ្មី* [ដែលមិនមានវិវាទជាមួយសម្បទានដីនិងសម្បទានព្រៃឈើមានស្រាប់] *នឹងត្រូវបានជ្រើសរើសនៅទីណាដែលផលប៉ះពាល់លើធនធានសង្គមនិងបរិស្ថាននៅក្នុងតំបន់នោះត្រូវបានកាត់បន្ថយជាអប្បបរមា។ ការពិចារណាបន្ថែមនឹងត្រូវបានផ្តល់ដល់ទីកន្លែងបម្រុងនៃតំបន់តាំងលំនៅឋានថ្មី ជាពិសេស នៅទីណាដែលទីកន្លែងនេះទន្ទ្រានលើតំបន់ដែលមានលក្ខណៈសំខាន់ផ្នែកអេកូឡូស៊ី និងដែលស្ថិតនៅជិតតំបន់ការពារ។*

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា: ច្បាស់ណាស់ ចេញពីឃ្លានេះ ម្ចាស់គម្រោងនិងអាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធនៅមិនទាន់បានកំណត់នៅឡើយទេថាតើការតាំងលំនៅឋានថ្មីរបស់ប្រជាជនរងផលប៉ះពាល់ អាច

ធ្វើបានឬទេ ដោយគិតគូរដល់ទាំងផលប៉ះពាល់បរិស្ថាន ឬ សក្តានុពលនៃការស្តារមុខរបរដែលត្រូវបាត់បង់ក្រោយពេលតាំងលំនៅឋានថ្មី និង ថ្លៃចំណាយនៃការធ្វើដូច្នេះ ។ បើគ្មានព័ត៌មានលម្អិតនេះទេ លទ្ធភាពផ្នែកសេដ្ឋកិច្ចនៃគម្រោងនេះមិនអាចត្រូវបានគេប៉ាន់ស្មានឱ្យបានត្រឹមត្រូវឡើយ ។

*ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន: ការធ្វើផែនការនិងការរៀបចំថវិកាសម្រាប់ជំនួយគ្រោះអាសន្ន និង សំណង នឹងត្រូវបានផ្តល់ជូនប្រជាជនរងផលប៉ះពាល់ [ក្នុងករណី] មានការបាក់ទំនប់ដែលបណ្តាលមកពីកត្តាធម្មជាតិ ។*

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ខកខានមិនបានដាក់បញ្ចូលចំណុចនេះជាថ្លៃចំណាយគម្រោងមួយទេ។ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ក៏មិនបានកំណត់ផងទេថាតើអ្នកណានឹងទទួលខុសត្រូវលើការផ្តល់ជំនួយនិងសំណងនេះ និង ថាតើអាជ្ញាធរណានឹងទទួលខុសត្រូវលើការធានាឱ្យបានថាប្រាក់បានទៅដល់ដៃប្រជាជនរងផលប៉ះពាល់ ។ បើគ្មានព័ត៌មានលម្អិតនេះទេ លទ្ធភាពផ្នែកសេដ្ឋកិច្ចនៃគម្រោងនេះមិនអាចត្រូវបានគេប៉ាន់ស្មានឱ្យបានត្រឹមត្រូវឡើយ ។

**ផលផល**

*ជម្រើសទីតាំងទំនប់ណាមួយនៃជម្រើសទាំងពីរនេះនឹងបង្អាក់ការធ្វើដំណើរបំលាស់ទីរបស់មច្ឆាជាតិនៅក្នុងទន្លេទាំងពីរ ... ។ របាយការណ៍សិក្សាលទ្ធភាពអនុវត្តសម្រាប់ប្លង់ទំនប់មិនបានដាក់បញ្ចូលរចនាសម្ព័ន្ធណាមួយសម្រាប់ការឆ្លងកាត់របស់មច្ឆាជាតិ ឬ វិធីសាស្ត្រផ្សេងទៀតដើម្បីទប់ស្កាត់ផលប៉ះពាល់លើមច្ឆាជាតិនៅក្នុងទន្លេសេសាននិងទន្លេស្រែពកទេ ។ សូម្បីតែប្រសិនបើមានរចនាសម្ព័ន្ធបម្រុងក្តី ក៏គេមិនដឹងអំពីភាពខុសគ្នាដែលរចនាសម្ព័ន្ធទាំងនេះអាចធ្វើឱ្យមានចំពោះការធ្វើដំណើរបំលាស់ទីរបស់មច្ឆាជាតិឡើយ ។*

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ លើកឡើងយ៉ាងត្រឹមត្រូវថាពុំមានវិធានការសម្រាលផលប៉ះពាល់ដែលគេដឹងសម្រាប់កែតម្រូវការខូចខាតចំពោះការធ្វើដំណើរបំលាស់ទីរបស់មច្ឆាជាតិ ក្រោយពេលដែលទំនប់រាំងខ្ទប់ផ្លូវធ្វើដំណើរ ។

*ទំនប់នេះទំនងជានឹងរាំងខ្ទប់មច្ឆាជាតិទាំងអស់ដែលធ្វើដំណើរឡើងចុះទន្លេទាំងពីរនេះនាអនាគត ដែលធ្វើឱ្យការខូចខាតមិនត្រឹមតែលើអេកូឡូស៊ីនៃទន្លេទាំងនេះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើរបបអាហារនិងមុខរបររបស់ប្រជាជនប្រហែល ៣០.០០០ នាក់ដែលរស់នៅក្នុងភូមិនៅតាមដងទន្លេខ្សែទឹកខាងលើនៃទីតាំងទំនប់ ។* គេប៉ាន់ស្មាន

*ថាគ្រួសារនីមួយៗអាចទទួលទានត្រីដោយចំណាយទឹកប្រាក់ចំនួនពី ២០០ ដុល្លារអាមេរិក ដល់ ៤០០ ដុល្លារអាមេរិក រៀងរាល់ឆ្នាំ។*

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ប៉ាន់ស្មានថាការបាត់បង់មច្ឆាជាតិរបស់ប្រជាជនចំនួន ៣០.០០០ នាក់ដែលរស់នៅខ្សែទឹកខាងលើទំនប់មានតម្លៃប្រហែលពី ២០០ ដុល្លារអាមេរិក ដល់ ៤០០ ដុល្លារអាមេរិករៀងរាល់ឆ្នាំ។ ដោយសន្មតថាគ្រួសារទំហំមធ្យមគឺមានសមាជិកប្រាំនាក់ តួលេខនេះបង្ហាញទឹកប្រាក់បាត់បង់សរុបចំនួនពី ១,២ ដុល្លារអាមេរិក ដល់ ២,៤ ដុល្លារអាមេរិកក្នុងមួយឆ្នាំ។ សូមកត់សម្គាល់ថាចំនួននេះទំនងជាគឺជាការប៉ាន់ស្មានមិនគ្រប់គ្រាន់ដ៏ទាបមួយនៃការបាត់បង់ជាក់ស្តែង ដោយសារតួលេខនេះមិនរាប់បញ្ចូលការបាត់បង់ជលផល ដែលត្រូវទទួលរងដោយប្រជាជននៅខ្សែទឹកខាងក្រោមទេ។ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ចង្អុលបង្ហាញថាជលផលនៅក្នុងខ្សែទឹកខាងក្រោមទន្លេមេគង្គ ពោលគឺតំបន់ដីសណ្តរមេគង្គនៅប្រទេសវៀតណាម ក៏ដូចជា ទន្លេសាប នឹងត្រូវរងផលប៉ះពាល់។ សូមកត់សម្គាល់ផងដែរថា

*ការសម្រាលផលប៉ះពាល់: សំណងប្រចាំឆ្នាំគ្រប់គ្រាន់ ដោយផ្អែកលើជលផលបាត់បង់ នឹងត្រូវបានផ្តល់ជូនគ្រួសារនៅតាមដងទន្លេស្រែពកនិងទន្លេសេសាន ដែលត្រូវបានព្យាករថានឹងត្រូវរងផលប៉ះពាល់ដោយការបាត់បង់មច្ឆាជាតិ ដោយសារប្រហែល ៩៥ ភាគរយនៃការបរិភោគប្រូតេអ៊ីនប្រចាំថ្ងៃរបស់ពួកគេ គឺពឹងអាស្រ័យលើមច្ឆាជាតិបានពីទន្លេទាំងពីរនេះ។ សំណងអាចត្រូវបានផ្តល់សម្រាប់គំនិតផ្តួចផ្តើមកែលម្អជីវភាព ប៉ុន្តែ សំណងប្រចាំឆ្នាំពេញលេញនឹងត្រូវបានផ្តល់ដោយម្ចាស់គម្រោង រហូតដល់ពេលដែលគេអាចបង្ហាញបានថាគំនិតផ្តួចផ្តើមកែលម្អជីវភាពទទួលបានជោគជ័យនិងមាននិរន្តរភាព។ ការកំណត់នេះនឹងត្រូវបានធ្វើដោយអ្នកវាយតម្លៃឯករាជ្យមួយ។*

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា: មុនពេលសន្យាថានឹងយកអ្នកវាយតម្លៃឯករាជ្យមួយមកឱ្យវាយតម្លៃលើអ្វីដែលមានឬគ្មានលក្ខណៈ "និរន្តរភាព" និង "ជោគជ័យ" ប្រជាជនកម្ពុជាមានសិទ្ធិត្រូវដឹងថាតើរាជរដ្ឋាភិបាលកម្ពុជាមានបំណងធានាឱ្យបានថាម្ចាស់គម្រោងនឹងទូទាត់ "សំណងប្រចាំឆ្នាំពេញលេញ" សម្រាប់ការបាត់បង់ប្រាក់ចំណូលនិងជលផលយ៉ាងដូចម្តេច។ តើគ្រួសាររងផលប៉ះពាល់នឹងត្រូវបានរំពឹងថានឹងត្រូវបង្ហាញភស្តុតាងនៃការបាត់បង់ជលផលឬប្រាក់ចំណូលយ៉ាងដូចម្តេច? តើមានអ្វីកើតឡើង ប្រសិនបើប្រជាជនចំនួន ១០០.០០០ នាក់ផ្តល់ភស្តុតាងនៃការបាត់បង់ ប៉ុន្តែ ក្រុមហ៊ុនបានគ្រោងថវិកាតែសម្រាប់ប្រជាជនចំនួន ៣០.០០០ នាក់? តើក្របខ័ណ្ឌគតិយុត្តិ និង ក្របខ័ណ្ឌកិច្ចសន្យាមាននៅទីណាដើម្បីធានាឱ្យបានថាម្ចាស់គម្រោងត្រូវបង់សំណង និងថាប្រជាជនរងផលប៉ះពាល់ ទាំងអស់ត្រូវបានសងយ៉ាងយុត្តិធម៌តាមតម្លៃទីផ្សារសម្រាប់ការបាត់បង់របស់ពួកគេ?

## ការជួយសម្រាលផលប៉ះពាល់សម្រាប់មុខរបរដែលបាត់បង់

*កម្មវិធីទ្រទ្រង់កសិកម្មនឹងត្រូវបានផ្តល់ជូនប្រជាជនរងផលប៉ះពាល់ ក្នុងអំឡុងពេលគ្រប់គ្រាន់មួយដើម្បីជួយឱ្យប្រជាជនអាចមានមុខរបរប្រកបដោយចីរភាព។ កម្មវិធីនេះ រួមមានការចិញ្ចឹមសត្វ ដូចជា គោ ក្របី មាន់ ទា និង សត្វផ្សេងទៀត។*

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាៈ វាគឺជាការងាយស្រួលដែលអ្នកអភិវឌ្ឍគម្រោងផ្តល់អនុសាសន៍នូវ "កម្មវិធីមុខរបរ" បែបនេះ ប៉ុន្តែ វាមានការលំបាក ចំណាយប្រាក់ច្រើន និង ចំណាយពេលច្រើនដើម្បីអនុវត្តប្រកបដោយជោគជ័យ ដូចដែលបទពិសោធន៍នៅទំនប់វារីអគ្គិសនីនៅប្រទេសឡាវក្នុងទសវត្សរ៍កន្លងមកបង្ហាញអញ្ចឹង។ យើងនឹងមានទំនុកចិត្តកាន់តែច្រើនឡើងលើអនុសាសន៍បែបនេះប្រសិនបើម្ចាស់គម្រោងអាចផ្តល់ភស្តុតាងថាកម្មវិធីបែបនេះមានបានដំណើរការល្អនៅទីកន្លែងផ្សេងនៅប្រទេសកម្ពុជា ឬ នៅប្រទេសជិតខាង។ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ពុំមានផ្តល់ការចង្អុលបង្ហាញថាអាជ្ញាធរកម្ពុជាបានត្រៀមលក្ខណៈដើម្បីត្រួតពិនិត្យលើកម្មវិធីនេះ។ តើកិច្ចសន្យាសាងសង់-ដំណើរការ-ផ្ទេរ (BOT) នឹងតម្រូវឱ្យរាជរដ្ឋាភិបាលកម្ពុជាខ្ចីមូលនិធិពីទីភ្នាក់ងារផ្តល់ជំនួយលោកខាងលិចដើម្បីទូទាត់ថ្លៃចំណាយនៃកម្មវិធីទាំងនេះ □ដូចជាករណីនៃគម្រោងវារីអគ្គិសនីណាមធឿន២ នៅប្រទេសឡាវ ឬទេ? ប្រសិនបើរាជរដ្ឋាភិបាលខ្ចីមូលនិធិដើម្បីបង់ថ្លៃកម្មវិធីសម្រាលផលប៉ះពាល់ជាជាងការកំណត់ឱ្យអគ្គិសនីវៀតណាមបង់ប្រាក់ចេញពីប្រាក់ចំណូលគម្រោងរបស់ខ្លួន តើរាជរដ្ឋាភិបាលនឹងសងមូលនិធិទាំងនោះវិញយ៉ាងដូចម្តេច? ហេតុអ្វីបានជាថ្លៃចំណាយទាំងនេះគប្បីត្រូវបានរ៉ាប់រងដោយរាជរដ្ឋាភិបាលកម្ពុជា និងជាចុងក្រោយ អ្នកបង់ពន្ធកម្ពុជា? ចំណុចនេះគប្បីត្រូវបានពន្យល់ជាសាធារណៈនៅប្រទេសកម្ពុជា និង ត្រូវអាស្រ័យលើ ការយល់ព្រមសាធារណៈមុនពេលមានការយល់ព្រមបន្ថែមណាមួយលើគម្រោងសេសានក្រោម២។

បើគ្មានក្របខ័ណ្ឌកិច្ចសន្យាមួយរវាងម្ចាស់គម្រោងនិងរាជរដ្ឋាភិបាលកម្ពុជាស្តីពីសំណងទេនោះ ប្រជាជនរងផលប៉ះពាល់គ្មានសង្ឃឹមថានឹងបានឃើញសំណងប្រកបដោយយុត្តិធម៌ឡើយ ចំពោះមុខប្រវត្តិនៃអគ្គិសនីវៀតណាមមកដល់ពេលនេះ។ នីតិវិធីបទបញ្ញត្តិត្រួតពិនិត្យ គប្បីត្រូវត្រូវបានបង្កើតនិងអនុម័តដោយអាជ្ញាធររាជរដ្ឋាភិបាល តំណាងរាជរដ្ឋាភិបាលតាមអាណត្តិជាប់ឆ្នោត និង ប្រជាជនរងផលប៉ះពាល់ មុនពេលមានការយល់ព្រមបន្ថែមទៀតលើគម្រោង។

## វិវាទដីធ្លី

*ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានៈ អាងបម្រុងនេះនឹងជនលិចសម្បទានដីចំនួនប្រាំ និង សម្បទានព្រៃឈើមួយរបស់ក្រុមហ៊ុនដែលមានអាជ្ញាប័ណ្ណរួចហើយនិងដែលកំពុងដំណើរការ - លើផ្ទៃដីសរុបទំហំ ១០.៣៩៩.៧៥៨ ហិកតា។ ក្រុមហ៊ុនប្រតិបត្តិគម្រោង រួមជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នឹងសហការជាមួយស្ថាប័នមានសមត្ថកិច្ចដើម្បីដោះស្រាយវិវាទដីធ្លី។*

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាៈ អ្វីដែលមិនច្បាស់នោះ គឺថាតើសម្បទានិកទាំងនេះមានសិទ្ធិទទួលសំណងឬទេ ហើយប្រសិនបើមាន តើក្នុងអត្រានិងល័ក្ខខ័ណ្ឌអ្វីខ្លះ? បើគ្មានព័ត៌មាននេះ និង ក្របខ័ណ្ឌកិច្ចសន្យាមានសុពលភាពតាមផ្លូវច្បាប់មួយសម្រាប់បង់ថ្លៃសំណងទេនេះ គេមិនអាចធ្វើការវាយតម្លៃលើលទ្ធភាពសេដ្ឋកិច្ចរបស់គម្រោងបានឡើយ។ ប្រជាជនមូលដ្ឋានអាចអះអាងយ៉ាងសមហេតុផលថាគឺពួកគេទេដែលគឺជាអ្នកមានសិទ្ធិទទួលសំណងសម្រាប់ការបាត់បង់ដីធ្លីចំពោះអាងស្តុកគម្រោងសេសានក្រោម២ ជាជាងសម្បទានិក ដោយសារដីនោះធ្លាប់គឺជាដីរបស់ពួកគេមុនពេលត្រូវបានប្រែក្លាយទៅជាសម្បទាន។ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ខកខានមិនបានបង្ហាញថាអាជ្ញាធរនឹងត្រៀមលក្ខណៈរួចហើយដើម្បីដោះស្រាយបញ្ហាទាំងនេះប្រកបដោយសមត្ថភាព មុនពេលមានការយល់ព្រមចុងក្រោយលើគម្រោង។

## ការតាំងលំនៅឋានថ្មី

*ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានៈ ប្រជាជនប្រហែលជា ៥.០០០ នាក់ ឬ គ្រួសារប្រហែល ១.០០០ នឹងបាត់បង់អ្វីៗទាំងអស់ចំពោះអាងស្តុករបស់ទំនប់ រួមមានគេហដ្ឋាន សួនដំណាំ វាលស្រែ អណ្តូងទឹក សាលារៀន វត្តអារាម និង ទីកន្លែងសហគមន៍ផ្សេងទៀត។ ម្យ៉ាងទៀត ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិយាយថាតំបន់បម្រុងសម្រាប់ការតាំងលំនៅឋានថ្មី "មានទំនាស់ជាមួយសម្បទានព្រៃឈើ" និង ជម្រកសត្វព្រៃ។*

*ទីតាំងសម្រាប់ការតាំងលំនៅឋានថ្មីត្រូវបានផ្តល់ជាអនុសាសន៍ និង គប្បីមានគុណភាពស្មើឬប្រសើរជាងអ្វីដែលពួកគេមាននៅពេលបច្ចុប្បន្ននេះ។ ទីតាំងសម្រាប់ការតាំងលំនៅឋានថ្មីនឹងត្រូវស្ថិតនៅទីកន្លែងណាដែលពុំមានផលប៉ះពាល់អវិជ្ជមានលើធនធានធម្មជាតិនិងសង្គម។ សំណងចំពោះទ្រព្យសម្បត្តិ គប្បីឆ្លុះបញ្ចាំងតម្លៃពិតប្រាកដនៅទីផ្សារក្នុងមូលដ្ឋាន និង ត្រូវបានផ្តល់មុនពេលដែលការសាងសង់ចាប់ផ្តើម។ សំណងនិងការតាំងលំនៅឋានថ្មី ត្រូវ*

*អនុវត្តស្របតាមរបាយការណ៍មួយស្តីពីការតាំងលំនៅឋានថ្មី ដែលត្រូវបានរៀបចំដោយក្រុមសិក្សារបស់ក្រុមហ៊ុន PECC1 ។*

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ គប្បីបង្ហាញឱ្យបានច្បាស់ថាតើ "ថ្លៃចំណាយជាក់ស្តែង" ទាំងនេះមានអ្វីខ្លះ - មានតែសេចក្តីសង្ខេបនៃតម្លៃប៉ាន់ស្មានប៉ុណ្ណោះដែលត្រូវបានផ្តល់ដោយគ្មានផ្តល់ការរាយលម្អិត ឬ ការពន្យល់ឡើយ ។

**គុណភាពទឹក**

*ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន: គុណភាពមិនល្អនៃទឹកទន្លេនៅក្នុងអំឡុងពេលសាងសង់ នឹងប៉ះពាល់ដល់ការផ្គត់ផ្គង់ទឹកតាមគ្រួសារនៅខ្សែទឹកខាងក្រោមនៃសហគមន៍ភ្លុក ក៏ដូចជា ការផ្គត់ផ្គង់ទឹកនៃខេត្តស្ទឹងត្រែង ផងដែរ ។ សហគមន៍ទាំងឡាយនៅខ្សែទឹកខាងក្រោមនឹង [ត្រូវ] ចំណាយប្រាក់ច្រើនជាងមុនដើម្បីសម្អាតទឹក ជាពិសេសការផ្គត់ផ្គង់ទឹកនៅទីរួមខេត្តស្ទឹងត្រែង ។ គុណភាពទឹកមិនល្អ នឹងប៉ះពាល់ដោយផ្ទាល់ដល់សុខភាពរបស់ប្រជាជនដែលប្រើទឹកទន្លេសេសានដោយគ្មានការសម្អាត ជាពិសេស ឃុំភ្លុក ដែលនៅទីនោះ ប្រជាជនមានការព្រួយបារម្ភអំពីផលប៉ះពាល់សុខភាពនៃការប្រើទឹកមិនបានសម្អាត ដូចជា ជម្ងឺស្បែកនិងភ្នែក និង ជម្ងឺរាគរូស ជាដើម ។*

*ការសម្រាលផលប៉ះពាល់: ការពិនិត្យមើលគុណភាពទឹកខ្សែទឹកខាងលើនិងខ្សែទឹកក្រោមនៃគម្រោង ត្រូវធ្វើឱ្យបានទៀងទាត់ដើម្បីធានាឱ្យបានថាគុណភាពទឹកនៅក្នុងអំឡុងពេលសាងសង់មិនប៉ះពាល់ធ្ងន់ធ្ងរដល់រុក្ខជាតិ និងសត្វរស់នៅក្នុងទឹក និង មនុស្សដែលប្រើទឹកទន្លេសេសាននៅខ្សែទឹកខាងក្រោមនៃគម្រោង ។*

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា: ការធ្វើតេស្តគុណភាពទឹកមិនមានធ្វើអ្វីទេដើម្បី "ធានាគុណភាពទឹក" នៅក្នុងទន្លេសេសាន។ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ គប្បីផ្តល់អនុសាសន៍ថាម្ចាស់គម្រោងត្រូវបង់ប្រាក់សម្រាប់ថ្លៃចំណាយនៃការសម្អាតទឹកនៅខ្សែទឹកខាងក្រោម ក៏ដូចជាសម្រាប់សេវាសុខភាពថ្នាំពេទ្យ ។ល។ ផងដែរ ក្នុងករណីមានជម្ងឺទាក់ទិននឹងការសាងសង់និងការដំណើរការទំនប់។ ថ្លៃចំណាយទាំងនេះអាចប៉ះពាល់ជាអវិជ្ជមានលើលទ្ធភាពសេដ្ឋកិច្ចនៃគម្រោង និង គប្បីត្រូវបានវាយតម្លៃ និង ដាក់បញ្ចូលក្នុងការវិភាគសេដ្ឋកិច្ចរបស់គម្រោង មុនពេលធ្វើសេចក្តីសម្រេចចិត្តចុងក្រោយ ។

**អភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ច**

*ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន: ប្រជាជននៅតាមទន្លេសេសាននិងទន្លេស្រែពក ពឹងអាស្រ័យលើការធ្វើកសិកម្ម នេសាទ ប្រមូលអនុផលព្រៃឈើ និង ការចិញ្ចឹមសត្វ សម្រាប់ជីវភាពរបស់ខ្លួន។ នៅក្នុងអំឡុងពេលនៃការដំណើរការគម្រោង ប្រជាជនប្រហែល ៣០០.០០០ នាក់នឹងត្រូវរងផលប៉ះពាល់ដោយការបាត់បង់ធនធានទាំងនេះ។*

*សហគមន៍ទាំងឡាយត្រូវបានរំពឹងថានឹងត្រូវបាត់បង់ផលិតផលព្រៃឈើនិងកសិកម្ម (ស្រូវ ដើមឈើហូបផ្លែ ដំណាំផ្សេងទៀត និង សារពើរុក្ខជាតិ) ការងារ (អ្នករត់ទូកដរ) និង ការចុះថយផលិតកម្មត្រីដែលគឺជាអាហារដ៏សំខាន់ខ្លាំងមួយ (បន្ទាប់ពីស្រូវ) សម្រាប់ប្រជាជននៅក្នុងតំបន់គម្រោង ក៏ដូចជា នៅខេត្តស្ទឹងត្រែងនិងខេត្តរតនគិរី នៅខ្សែទឹកខាងលើនិងខ្សែទឹកខាងក្រោមនៃទីតាំងទំនប់ផងដែរ។ ហេតុដូច្នេះ ផលប៉ះពាល់លើជីវភាពរបស់ប្រជាជនដែលរស់នៅខ្សែទឹកខាងលើនៃទីតាំងទំនប់ គឺមានលក្ខណៈធ្ងន់ធ្ងរ។* ***តាមពិត ផ្អែកលើការធ្វើអង្កេតសង្គមរបស់ក្រុមហ៊ុន KCC កាលពីខែ កុម្ភៈ ឆ្នាំ ២០០៨ ៨៥ ភាគរយនៃប្រជាជនដែលគេបានសម្ភាសន៍នៅក្នុងតំបន់បម្រុងគម្រោងបានលើកឡើងថាពួកគេមិនចង់ឱ្យមានការសាងសង់ទំនប់នេះទេ ដោយសារវានឹងប៉ះពាល់ដល់អាយុជីវិតពួកគេយ៉ាងខ្លាំង [ការសង្កត់ធ្ងន់ត្រូវបានបន្ថែម]។***

*គម្រោងនេះ ក៏នឹងប៉ះពាល់ផងដែរដល់សុខភាពរបស់ប្រជាជន (គុណភាពទឹកមិនល្អ) បន្ថយផលិតកម្មត្រី បំផ្លាញសួនដំណាំតាមច្រាំងទន្លេនិងឆ្នេរទន្លេ និង ជួនកាល សម្លាប់សត្វនិងអ្នកភូមិ ដោយសាររបបលំហូរប្រែប្រួល និងទឹកជំនន់ភ្លាមៗដែលបណ្តាលមកពីការបញ្ចេញទឹកពីទំនប់នៅក្នុងអំឡុងពេលដំណើរការ។*

*វិធានការសម្រាលផលប៉ះពាល់: ក្រុមហ៊ុនប្រតិបត្តិគម្រោងនឹងទទួលខុសត្រូវលើការផ្តល់សំណងជូនដល់ប្រជាជនរងផលប៉ះពាល់ផ្ទាល់និងប្រយោលនៅខ្សែទឹកខាងលើនិងខ្សែទឹកខាងក្រោមនៃតំបន់គម្រោង រួមទាំងសហគមន៍ទាំងឡាយនៅតាមដងទន្លេទាំងពីរនៅខេត្តរតនគិរីផងដែរ។ សំណងត្រូវរួមមាន: ការកសាងសមត្ថភាពមុខរបរថ្មី មូលនិធិអាជីវកម្មតូចតាច កម្មវិធីអភិវឌ្ឍន៍ប្រព័ន្ធកសិកម្ម និង មូលនិធិអភិវឌ្ឍន៍សហគមន៍ផ្សេងទៀត។ មូលនិធិសំណងប្រចាំឆ្នាំដែលស្មើនឹងការបាត់បង់មច្ឆជាតិប្រចាំឆ្នាំនៅក្នុងទន្លេទាំងពីរ (២,៥៦ លានដុល្លារ)។*

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា: តើគេគិតយ៉ាងដូចម្តេចអំពីការបាត់បង់ប្រាក់ចំណូលពីផលព្រៃឈើនិង អនុផលព្រៃឈើ វាលស្រែ និង ការបាត់បង់ដំណាំផ្សេងទៀត? ប្រសិនបើមាន តើប្រជាជនមូលដ្ឋាន

មានតួនាទីអ្វីខ្លះក្នុងការសម្រេចថាតើអ្វីទៅដែលគឺជាសំណងប្រកបដោយយុត្តិធម៌? តើអ្នកណានឹងត្រួតពិនិត្យមើលការចាត់ចែងសំណងដែលមិនចំណុះម្ចាស់គម្រោង?

**ការផ្គត់ផ្គង់ទឹក**

*ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានៈ ផលប៉ះពាល់ពីគុណភាពឬបរិមាណទឹកចេញពីរោងចក្រវារីអគ្គិសនីនឹងនាំទៅដល់ការបាត់បង់ខាងសេដ្ឋកិច្ចដោយសារហានិភ័យសុខភាព និង តម្លៃខ្ពស់នៃការផ្គត់ផ្គង់ទឹក។ វិធានការសម្រាលផលប៉ះពាល់ រួមមានៈ ការសម្អាតទឹកអាង និង ការធានាឱ្យបានថាលំហូរបរិស្ថានគ្រប់គ្រាន់ត្រូវបានរក្សាទុកនៅខ្សែទឹកខាងក្រោមនៃទំនប់ គ្រប់ពេលវេលាទាំងអស់។*

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាៈ តើអ្នកណាសម្រេចថាអ្វីគឺសមស្រប នៅពេលណា និង ក្នុងតម្លៃអ្វី ចំពោះអ្នកណា? ជាថ្មីម្តងទៀត គ្មានក្របខ័ណ្ឌបទបញ្ញត្តិត្រូវបានបង្ហាញសម្រាប់សម្រេចអំពីលំហូរបរិស្ថានសមស្របមួយ - អនុសាសន៍នេះប៉ះពាល់ទិន្នផលថាមពលនៃទំនប់ និង ដោយហេតុនេះ លទ្ធភាពសេដ្ឋកិច្ចរបស់វា។ បើគ្មានការវាយតម្លៃលើសេណារីយ៉ូលំហូរបរិស្ថានផ្សេងៗគ្នា និង ផលប៉ះពាល់របស់វាលើប្រាក់ចំណូលគម្រោង នោះលទ្ធភាពសេដ្ឋកិច្ចនៃគម្រោងសេសានក្រោម២ មិនអាចត្រូវបានអះអាងបានទេ។

**ផលប៉ះពាល់សរុប**

*ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានៈ ទំនប់សរុបចំនួនប្រាំកំពុងដំណើរការឬស្ថិតក្នុងការសាងសង់នៅលើទន្លេសេសាន ហើយទំនប់ចំនួនបីផ្សេងទៀតកំពុងស្ថិតនៅក្នុងដំណាក់កាលធ្វើផែនការសម្រាប់ទន្លេសេសាន រួមទាំងគម្រោងសេសានក្រោម២។ នៅលើទន្លេស្រែពក ទំនប់ចំនួន ៣ កំពុងដំណើរការឬស្ថិតក្រោមការសាងសង់ ហើយទំនប់ចំនួន ៥ ផ្សេងទៀតកំពុងស្ថិតនៅក្នុងដំណាក់កាលធ្វើផែនការ។ ... ការប្រែប្រួលកម្ពស់ទឹកនៅក្នុងទន្លេទាំងនេះកំពុងកើតឡើងរួចទៅហើយ ដោយមានផលប៉ះពាល់អវិជ្ជមានលើអេកូឡូស៊ីនៅខ្សែទឹកខាងក្រោម និង ប្រជាជនដែលរស់នៅជិតទន្លេទាំងនេះ។ គម្រោងវារីអគ្គិសនីទាំងអស់លើទន្លេសេសាននិងទន្លេស្រែពក កំពុងប៉ះពាល់ជីវភាពរួចទៅហើយ។ ផលប៉ះពាល់សរុបដែលបណ្តាលមកពីរោងចក្រវារីអគ្គិសនីបូកសរុបទាំងអស់លើទន្លេទាំងពីរនេះ រួមមានៈ ហានិភ័យសុខភាពជាមួយគុណភាពទឹកមិនល្អ ការថយចុះច្រើននៃផលិតកម្មត្រី ការបាត់បង់សួនដំណាំ ការខូចខាតទ្រព្យសម្បត្តិ និង ការបាត់បង់អាយុជីវិតរបស់សត្វនិងអ្នកភូមិ ដោយសារការប្រែប្រួលរបបលំហូរទឹក និង ទឹកជន់ឡើងភ្លាមៗ*

*ដែលបណ្តាលមកពីការបញ្ចេញទឹកពីទំនប់ និង ការបាត់បង់ផ្ទៃដីព្រៃឈើដែលត្រូវបានប្រើសម្រាប់ការប្រមូលអនុផលព្រៃឈើ ។*

*វិធានការសម្រាលផលប៉ះពាល់: កិច្ចសហប្រតិបត្តិការល្អរវាងរដ្ឋាភិបាលទាំងពីរដើម្បីការពារសហគមន៍ទល់នឹងហានិភ័យណាមួយដែលបណ្តាលមកពីគម្រោងនៅខ្សែទឹកខាងលើ ។ ម្ចាស់គម្រោងនីមួយៗនឹងទទួលខុសត្រូវលើការផ្តល់សំណងជាប្រាក់និងការជួយគាំទ្រជីវភាពផ្សេងទៀតចំពោះប្រជាជនរងផលប៉ះពាល់ ។*

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា: រដ្ឋាភិបាលនៃប្រទេសកម្ពុជានិងវៀតណាម បាននិងកំពុងសន្យា "កិច្ចសហប្រតិបត្តិការល្អ" លើការកាត់បន្ថយការខូចខាតបណ្តាលមកពីទំនប់នៅភូមិភាគឦសាននៃប្រទេសកម្ពុជា អស់រយៈពេលជាងមួយទសវត្សន៍កន្លងមកហើយ ដោយគ្មានលទ្ធផលវិជ្ជមានច្រើនសម្រាប់អ្នកភូមិរងផលប៉ះពាល់ ។ ការយល់ព្រមលើគម្រោងដែលផ្អែកលើការអះអាងថាម្ចាស់គម្រោងនឹង "ទទួលខុសត្រូវ" នឹងធ្វើឱ្យប្រជាជនជាច្រើនស្ថិតនៅក្នុងហានិភ័យ ។

**ហេដ្ឋារចនាសម្ព័ន្ធជនបទ**

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា: ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះពិព័ណ៌នាដោយខុសនូវការធ្វើជំនួសហេដ្ឋារចនាសម្ព័ន្ធជនបទដែលត្រូវបានបំផ្លាញដោយគម្រោង ថាជាអត្ថប្រយោជន៍គម្រោង ។ អ្នកមិនអាចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរបស់ប្រជាជន រួចហើយ ហៅវាថាជា "អត្ថប្រយោជន៍" មួយ នៅពេលដែលវាត្រូវបានជំនួស ។ ថ្លៃចំណាយលើការធ្វើជំនួសទ្រព្យដែលត្រូវបានបំផ្លាញនិងសេវានានា គប្បីគឺជាផ្នែកមួយនៃថវិកាសម្រាប់ការតាំងលំនៅឋានថ្មីនិងសំណង និង ត្រូវដាក់បញ្ចូលជាថ្លៃចំណាយ មិនមែនជាអត្ថប្រយោជន៍ទេ ។

**សំណួរបន្ថែមអំពីថវិកា**

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា: របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ មិនមានបញ្ជាក់ទេ ថាតើប្រាក់ចំនួនប៉ុន្មាននឹងត្រូវបានបង់ឱ្យក្រុមហ៊ុនសម្បទានទាំងប្រាំមួយ និង ថាតើប្រាក់នេះនឹងចេញមកឬទេពីរាជរដ្ឋាភិបាលកម្ពុជា ឬ ប្រាក់ចំណូលគម្រោង ។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា: របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ខកខានមិនបានពន្យល់ ថាតើប្រាក់ចំនួន ៣០ លានដុល្លារអាមេរិកសម្រាប់ "ការដាំព្រៃឈើឡើងវិញ" នឹងត្រូវបានបែងចែកយ៉ាងដូចម្តេច នៅទីណា ដើម្បីគោលបំណងអ្វី និង ជូនអ្នកណា។ ព័ត៌មាននេះត្រូវតែផ្សព្វផ្សាយជាសាធារណៈ។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា: របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ប៉ាន់ស្មានថាប្រាក់រហូតដល់ចំនួន ២,៥ លានដុល្លារត្រូវតែបង់ជារៀងរាល់ឆ្នាំជូនដល់ប្រជាជនចំនួន ៣០.០០០ នាក់ដែលរស់នៅខ្សែទឹកខាងលើ សម្រាប់ការបាត់បង់ជលផល។ ពុំមានការនិយាយយោងដល់ប្រជាជនរាប់ម៉ឺននាក់នៅខ្សែទឹកខាងក្រោម ដែលមុខរបររបស់ខ្លួន ក៏រងហានិភ័យផងដែរ។ របាយការណ៍នេះបានត្រឹមតែនិយាយថាសំណងត្រូវតែបង់ជូនប្រជាជនទាំង ៣០.០០០ នាក់នេះនៅខ្សែទឹកខាងលើ រហូតដល់ពេលដែលកម្មវិធីជំនួសមុខរបរត្រូវបានបង្ហាញថាទទួលបាន "ជោគជ័យ" និង មាន "និរន្តរភាព។" គេមិនដឹងច្បាស់ទេថាតើតួលេខសម្រាប់សំណងជាសាច់ប្រាក់ផ្ទាល់នេះមានត្រូវបានដាក់បញ្ចូលនៅក្នុងការប៉ាន់ស្មានថ្លៃចំណាយលើការតាំងលំនៅឋានថ្មីនិងសំណងឬទេ។ ការពន្យល់ទាំងស្រុងតាមខ្ទង់នីមួយៗអំពីការបង់សំណង និង ថ្លៃចំណាយនៃកម្មវិធីផ្សេងទៀត គឺចាំបាច់សម្រាប់ការពិនិត្យមើលសាធារណៈ។ ប្រជាជនរងផលប៉ះពាល់ពីគម្រោង និង ប្រជាជនកម្ពុជាជាទូទៅ មានសិទ្ធិត្រូវដឹងថាតើសំណងអ្វីខ្លះនឹងត្រូវបានផ្តល់ជូនអ្នកណា មុនពេលដែលសេចក្តីសម្រេចចិត្តចុងក្រោយត្រូវបានធ្វើដើម្បីសាងសង់គម្រោងសេសានក្រោម២។

## ៧. អនុសាសន៍ស្តីពីសកម្មភាព

**ផ្អែកលើការពិនិត្យមើលឡើងវិញរបស់យើង យើងរកឃើញថាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងសេសានក្រោម ២ គឺជាមូលដ្ឋានមិនគ្រប់គ្រាន់មួយសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តវិនិយោគមាំមួន ហើយដោយហេតុនេះ សូមផ្តល់ជាអនុសាសន៍ថាការយល់ព្រមបន្ថែមទៀតនិងការចរចារនានាទាក់ទិននឹងគម្រោងសេសានក្រោម២ គប្បីត្រូវផ្អាករហូតដល់ពេលមួយដែលអ្នកអភិវឌ្ឍធ្វើការកែសម្រួលឡើងវិញនូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលជាទីពេញចិត្តរបស់ប្រជាជនទាំងអស់ដែលរងផលប៉ះពាល់ពីគម្រោងនៅតាមគ្រប់តំបន់រងផលប៉ះពាល់ទាំងអស់ ឬ បោះបង់ចោលគម្រោងនេះ ជាការគាំទ្រចំពោះជម្រើសផ្គត់ផ្គង់អគ្គិសនីនានា ដែលមានថ្លៃចំណាយទាបជាងនិងហានិភ័យតិចជាង។**

**ចប់/**

**គប្បីសរសេរឃ្លាខ្លីមួយដែលថា រាជរដ្ឋាភិបាលកម្ពុជាគប្បីទាមទារគោលការណ៍ណែនាំច្បាស់លាស់របស់អគ្គិសនីវៀតណាមអំពីរបៀបដែលពួកគេនឹងផ្តល់មូលនិធិដល់សំណង ការសម្រាលផលប៉ះពាល់ និង កម្មវិធីមុខរបរ ។ ម្យ៉ាងទៀត ជាម្ចាស់ BOT និង អ្នកទទួលខុសត្រូវលើការសាងសង់ ក្រុមហ៊ុន PECC1 និង/ឬ EVN គប្បីត្រូវបានចាប់ឱ្យទទួលខុសត្រូវលើគ្រប់អន្តរាយទាំងអស់ដែលបណ្តាលមកពីគម្រោង ទោះបីជាដោយចៃដន្យឬដោយចេតនាក្តី ។**